# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១០
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១០

(០១/០៥/២០១០-៣១/០៥/២០១០)

អនុវត្តតាមផែនការជាតិឆ្នាំ២០១០ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនដែលបានដាក់ចេញកាលពីខែមេសាឆ្នាំ២០១០ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងវិស័យឯកជននានា ពង្រឹងនូវកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យក្នុងការ ប្រយុទ្ធប្រឆាំងគ្រឿងញៀនទទួលបានលទ្ធផលល្អប្រសើរ ។

## I. សភាពការណ៍គ្រឿងញៀន

### *១. សភាពការណ៍គ្រឿងញៀនអន្តរជាតិ*

នៅថ្ងៃទី២៧-២៩ខែមេសាឆ្នាំ២០១០ នៅទីក្រុងរីយ៉ូដឺហ្សាណេរ៉ូ ប្រទេសប្រេស៊ីល បានបើកសន្និសីទស្តីពីការអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ លើកទី២៧ (IDEC) ។ បណ្តាប្រទេសជាសមាជិកទាំងអស់បានធ្វើការវាយតម្លៃថា ទោះបីដំណាំគ្រឿងញៀនធម្មជាតិមានការថយចុះ ប៉ុន្តែបណ្តាប្រទេសនៅលើពិភពលោកកំពុងប្រឈមនឹងការកើនឡើងនូវការផលិតគ្រឿងញៀនសំយោគ ។ ក្នុងខណៈដែលបណ្តាប្រទេសមួយចំនួនបាន និងកំពុងជួបនូវវិបត្តិសេដ្ឋកិច្ចជាសកល ក្រុមពាណិជ្ជករមួយចំនួនបានឆ្លៀតឱកាសទំនាក់ទំនងជាមួយក្រុមឧក្រិដ្ឋជនគ្រឿងញៀន ដើម្បីស្វែងរកជំនួយផ្នែកហិរញ្ញវត្ថុ តាមរយៈការដឹកជញ្ជូនគ្រឿងញៀនឆ្លងដែន ដោយជ្រកក្រោមរូបភាពនៃការធ្វើពាណិជ្ជកម្មស្របច្បាប់ និងការលាងលុយកខ្វក់ ។ បណ្តាប្រទេសអាស៊ានភាគច្រើនមានការព្រួយបារម្ភអំពីវត្តមានក្រុមដឹកជញ្ជូនគ្រឿងញៀនឆ្លងដែនកោះតៃវ៉ាន់ និង ក្រុមមកពីអាហ្វ្រិកខាងលិច ដែលកំពុងធ្វើសកម្មភាពខ្លាំងជាងគេនៅតំបន់អាស៊ី-បូពា ។ ដោយឡែក ដំណាំអាភៀននៅប្រទេសឡាវបានកើនឡើងវិញ បន្ទាប់

ពីអង្គការUNODC និង DEAសហរដ្ឋអាមេរិក បានកាត់បន្ថយនូវគំរោងអភិវឌ្ឍន៍មួយចំនួនចេញពីប្រទេសនេះ ប៉ុន្តែដំណាំអាភៀនទាំងនោះស្ថិតនៅក្រោមការតាមដានឃ្លាំមើល និង គ្រប់គ្រងរបស់រដ្ឋាភិបាលឡាវ ។

### *២.សភាពការណ៍គ្រឿងញៀននៅកម្ពុជា*

ខែឧសភានេះ ពួកឈ្មួញគ្រឿងញៀនក្នុងតំបន់បានបន្តល្បិចកល ក្នុងការធ្វើសកម្មភាពដឹកជញ្ជូនគ្រឿងញៀនពីតំបន់ត្រីកោណមាសចូលមកកម្ពុជាតាមច្រកភាគឦសានប្រទេស ដើម្បីផ្គត់ផ្គង់ការប្រើប្រាស់ និងមួយចំនួននាំបន្តទៅក្រៅប្រទេស ជាពិសេសតាមច្រកព្រំដែនភាគពាយ័ព្យ ។ សកម្មភាពនេះ យើងក្តាប់បានតាមរយៈការបង្ក្រាបករណីជាក់ស្តែងដែលបានកើតឡើងនៅរាជធានីភ្នំពេញ និង បណ្តាខេត្តមួយចំនួន ដូចជា ខេត្តប៉ៃលិន ខេត្តពោធិសាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តកំពត ខេត្តព្រះសីហនុ ។ កត់សំគាល់ បណ្តាករណីដែលបង្ក្រាបទាំងនោះសុទ្ធសឹងជាករណីចរាចរនូវប្រភេទគ្រឿងញៀន មេតំហ្វេតាមីនគ្រាប់(WY) និង មេតំហ្វេតាមីន (ICE) ។ ដោយឡែក ស្នងការដ្ឋាននគរបាលខេត្តពោធិសាត់បង្ក្រាបប្រេងម្រះព្រៅភ្នំបាន១ករណី ដែលនេះគឺជាសញ្ញាបង្ហាញថា តំបន់នោះនៅតែមានការផលិតប្រេងម្រះព្រៅភ្នំនៅឡើយ ។

## II . **លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន :**

### *ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់ចង្អុលដឹកនាំ ណែនាំលើគ្រប់វិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ ការអនុញ្ញាតឱ្យក្រុមការងាររបស់អង្គការសហប្រជាជាតិ រួមមាន តំណាងការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម(UNODC), អង្គការសុខភាពពិភពលោក (WHO), អង្គការអេដស៍សហប្រជាជាតិ(UNAIDS), មូលនិធិសហប្រជាជាតិសំរាប់កុមារ(UNICEF) ចូលជួបពិភាក្សាអំពីការរៀបចំសេវាព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ និងអនុញ្ញាតឱ្យប្រតិភូនៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនចិន ចូលជួបសំដែងការគួរសមក្នុងឱកាសដែលអញ្ជើញមកកម្ពុជា ដើម្បីចូលរួមប្រជុំទ្វេភាគី កម្ពុជា-ចិន លើកទី១ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជាពីថ្ងៃទី ១៧ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ ។

ទន្ទឹមនោះ ដើម្បីអនុវត្តបានជោគជ័យនូវផែនការសកម្មភាពខាងលើ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ព្រមទាំងបានណែនាំឱ្យបង្កើតនូវផែនការប្រតិបត្តិគំរូ សំរាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ ដើម្បីធ្វើជាចំណុចដកពិសោធន៍សំរាប់ពង្រីកកិច្ចប្រតិបត្តិការឱ្យមានប្រសិទ្ធភាពទៅកាន់រាជធានី-ខេត្ត ទូទាំងប្រទេសនៅក្នុងឆមាសទី២ ឆ្នាំ២០១០ ។

## ១.ការកាត់បន្ថយតម្រូវការគ្រឿងញៀន :

ក្នុងខែឧសភានេះ តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, សាកលវិទ្យាល័យឯកទេសនៃកម្ពុជាសាខាខេត្តសៀមរាប, សកលវិទ្យាល័យបញ្ញាជាតិ និង សមាគមយុវជនខ្មែរ អគ្គលេខាធិការដ្ឋាន អជបគញ បានចូលរួមពិធីសំណេះសំណាលនិងផ្សព្វផ្សាយអប់រំអំពីសភាពការណ៍គ្រឿងញៀននៅកម្ពុជា និងគ្រោះថ្នាក់នៃគ្រឿងញៀនដល់លោកគ្រូ-អ្នកគ្រូ-សិស្សានុសិស្ស ព្រមទាំងចូលរួមជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាលស្តីពី "អប់រំបង្ការគ្រឿងញៀននិងវេទិកាសិល្បៈ" ក្នុងគោលបំណង ប្រមូលព័ត៌មាន ផ្តល់ចំណេះដឹង និង អនុសាសន៍ដែលទាក់ទងនឹងបញ្ហាគ្រឿងញៀន ដល់គ្រូនិងសិស្សានុសិស្ស ដើម្បីពួកគាត់មានសមត្ថភាពអាចធ្វើការអប់រំបន្តនៅតាមសាលារៀនតាមរយៈការសម្តែងសិល្បៈ សរុបមានសិស្ស និស្សិត ចំនួនប្រហែល៩០០នាក់ ។

តាមកម្មវិធីដែលផ្តល់ដោយស្ថានីយ៍ទូរទស្សន៍ CTN ក្រសួងអប់រំយុវជននិងកីឡា បានផ្តល់កិច្ចសម្ភាសន៍ក្រោមប្រធានបទស្តីពីការទទួលខុសត្រូវរបស់ក្រសួងអប់រំយុវជននិងកីឡា ក្នុងការអប់រំបង្ការការប្រើបំពានគ្រឿងញៀននៅក្នុងវិស័យសិក្សា ព្រមទាំងបានផ្តល់កិច្ចសម្ភាសន៍ដល់ស្ថានីយ៍ទូរទស្សន៍ **ទទក** ក្នុងកម្មវិធី **សមធម៌ប្រចាំសប្តាហ៍** ស្តីពីសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន ការស្តារនីតិសម្បទា និងវិធីសាស្ត្រក្នុងការផ្តាច់គ្រឿងញៀន ។

ជាមួយនេះដែរ អគ្គលេខាធិការដ្ឋានក៏បានចូលរួមនៅក្នុងកម្មវិធីកីឡាប្រដាល់ពានរង្វាន់ប្រាក់លានរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅស្ថានីយ៍ទូរទស្សន៍ប៉ុស្តិ៍បាយ័ន ។

ដោយឡែក បណ្តាខេត្ត និង សមាគមមួយចំនួន ក៏បានបន្តការយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន សរុបបានចំនួន ៣.០៣១ នាក់ ក្នុងនោះរួមមាន ÷

| **អង្គភាព** | **ខ្លឹមសារ** | **សមាសភាព** | **ចំនួន** |
|---|---|---|---|
| ខេត្តបាត់ដំបង (៣លើក) | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ | ៧៩៣ នាក់ |
| ខេត្តកណ្តាល | គ្រោះថ្នាក់នៃគ្រឿងញៀន | លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស | ១១៣ នាក់ |
| ខេត្តឧត្តរមានជ័យ(៤លើក) | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ | ១០៣ នាក់ |
| ខេត្តកំពង់ធំ | គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និង គ្រោះថ្នាក់នៃគ្រឿងញៀន | មេក្រុម១០ខ្នង លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស | ១.៧៦៩ នាក់ |
| ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ | ចុះផ្សព្វផ្សាយបំរាមមិនឱ្យប្រើប្រាស់គ្រឿងញៀន | តាមសណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត ចំនួន ១៩ កន្លែង | |
| ខេត្តតាកែវ (២លើក) | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ | ២៥៣ នាក់ |
| សរុប | | | ៣.០៣១ នាក់ |

## ២.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន :

ខែឧសភាឆ្នាំ២០១០ បង្ក្រាបបទល្មើសបាន **៣០ ករណី** ឃាត់ខ្លួនជនល្មើសចំនួន **៥១** នាក់( ប្រុស៤០

នាក់, ស្រី ១១នាក់) បញ្ជូនទៅតុលាការ ក្នុងនោះមាន ជនជាតិខ្មែរ **៤៩** នាក់ ( ប្រុស **៣៨** នាក់ ស្រី **១១**នាក់) វៀតណាម **២** នាក់ ( ប្រុស **២**) ។

**វត្ថុតាងចាប់យក** មេតំហ្វេតាមីន **WY ៥.២៩៧** គ្រាប់, ម្សៅមេតំហ្វេតាមីន **ICE ២៩០,៨៨** ក្រាម, អ៊ិចស្តាស៊ី **២៦**គ្រាប់, ម្សៅកេតាមីន ០,៤២ក្រាម, កញ្ឆាក្រៀម **៧៥២,៨៨**ក្រាម, រថយន្ត **២**គ្រឿង, ម៉ូតូ **៩**គ្រឿង ។

**អង្គភាពប្រតិបត្តិការបង្ក្រាបបទល្មើស រួមមាន :**

| ល.រ | អង្គភាពបង្ក្រាប | សរុបរួម | | | ចរាចរជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| ១ | មន្ទីរប្រឆាំងគ្រឿងញៀន | **៦** | **១២** | **២** | ៤ | ៨ | ២ | ២ | ៣ | ០ | ០ | ១ | ០ |
| ២ | រាជធានីភ្នំពេញ | **៨** | **១៧** | **៤** | ៦ | ១០ | ៤ | ២ | ៧ | ០ | | | |
| ៣ | កណ្តាល | **១** | **២** | **០** | | | | ១ | ២ | ០ | | | |
| ៤ | កំពង់ចាម | **២** | **២** | **០** | ២ | ២ | ០ | | | | | | |
| ៥ | ព្រះសីហនុ | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ៦ | សៀមរាប | **២** | **២** | **១** | ២ | ២ | ១ | | | | | | |
| ៧ | កំពត | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ៨ | បាត់ដំបង | **៣** | **៤** | **២** | ៣ | ៤ | ២ | | | | | | |
| ៩ | បន្ទាយមានជ័យ | **២** | **៦** | **០** | ២ | ៥ | ០ | | | | ០ | ១ | ០ |
| ១០ | ពោធិសាត់ | **១** | **០** | **០** | ១ | ០ | ០ | | | | | | |
| ១១ | ប៉ៃលិន | **៣** | **៤** | **២** | ៣ | ៤ | ២ | | | | | | |
| **សរុប** | | **៣០** | **៥១** | **១១** | **២៥** | ៣៧ | ១១ | **៥** | ១២ | ០ | **០** | ២ | ០ |

អគ្គលេខាធិការដ្ឋាន បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការប្រមូលទិន្នន័យសារធាតុគីមីផ្សំ ដែលមានអាជ្ញាប័ណ្ណនាំចូលប្រចាំខែឧសភាឆ្នាំ២០១០ សរុបមានចំនួន **7.021.632 Kgs** ក្នុងនោះមាន :

| **ឈ្មោះសារធាតុគីមី** | **ផ្តល់អាជ្ញាប័ណ្ណដោយ ក្រសួងសុខាភិបាល** | | **ផ្តល់អាជ្ញាប័ណ្ណដោយ ក្រសួង ឧស្សាហកម្ម** | | **ផ្តល់អាជ្ញាប័ណ្ណដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** | | **សរុប** | |
|---|---|---|---|---|---|---|---|---|
| | Kg | L | Kg | L | Kg | L | Kg | L |
| Formic Acid | | | 40.000 | | 41.260 | | **81.260** | |
| Glacial Acetic Acid | | | 236.220 | | 56.520 | | **292.740** | |
| Sodium Cabornate | | | | | 426.600 | | **426.600** | |
| Sodium Hydroxyde | | | | | 222.050 | | **222.050** | |
| Sodium Sulfate | | | | | 4.400.400 | | **4.400.400** | |
| Toluene | | | 180.000 | | 57.250 | | **237.250** | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| Methyl Ethyl Ketone | | | 15.000 | | 10.200 | | **25.200** | |
| Acetone | | | 20.000 | | 5.000 | | **25.000** | |
| Methylene Chloride | | | | | 30.182 | | **30.182** | |
| Costic Soda | | | 50.000 | | 16.500 | | **66.500** | |
| Soda Ash | | | | | 26.000 | | **26.000** | |
| Sodium Hyphochloride | | | | | 28.000 | | **28.000** | |
| Thinner | | | 85.750 | | 20.000 | | **105.750** | |
| Oxalic Acid | | | | | 4.600 | | **4.600** | |
| Ethyl Acetate | | | 25.000 | | | | **25.000** | |
| Xylene | | | 50.000 | | | | **50.000** | |
| Sulfuric Acid | | | 852.000 | | | | **852.000** | |
| HCL | | | 50.000 | | | | **50.000** | |
| Solvent | | | 73.000 | | | | **73.000** | |
| Phenyl Propanolamine | 100 | | | | | | **100** | |
| **TOTAL :** | **100** | | **1.676.970** | | **5.344.562** | | **7.021.632** | |

ដោយឡែក  កម្លាំងស្នងការដ្ឋាននគរបាលខេត្តពោធិសាត់  បានធ្វើការបង្ក្រាបប្រេងម្រះព្រៅភ្នំ១ករណី  និង ចាប់យកប្រេងម្រះព្រៅភ្នំចំនួន២៣ប៊ីដុង ស្មើនឹង ៩២៤គីឡូក្រាម, បំពង់ចំហុយ៦, ធុងស្តុំ១ និង ម៉ាស៊ីនកាត់ឈើ១។

### ៣‐ការព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និង  ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន  :

#### -ការព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

រាជរដ្ឋាភិបាលកម្ពុជា បានសំរេចផ្តល់របបជីវភាពជូនជនរងគ្រោះដោយសារគ្រឿងញៀន ដែលកំពុងស្នាក់នៅតាមមណ្ឌលបណ្តោះអាសន្នសំរាប់អប់រំ បន្សាប និង ព្យាបាលអ្នកញៀនគ្រឿងញៀនចំនួន ៦ កន្លែងគឺ :

១-មណ្ឌល ឱកាសខ្ញុំ រាជធានីភ្នំពេញ

២-មណ្ឌល ស្តារនីតិសម្បទាដល់ជនរងគ្រោះដោយសារគ្រឿងញៀន ខេត្តបាត់ដំបង

៣-មណ្ឌល បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តបាត់ដំបង

៤-មណ្ឌល បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ

៥-មណ្ឌល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ខេត្តសៀមរាប

៦-មណ្ឌល បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តព្រះសីហនុ

ដោយឡែក មណ្ឌលបណ្តោះអាសន្នសំរាប់ អប់រំ បន្សាប និង ព្យាបាលអ្នកញៀនគ្រឿងញៀន នៅឃុំកួលតាហែន ស្រុកបវេល របស់ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បាននិងកំពុងសាងសង់អាគារមន្ទីរពេទ្យ ក្រោមការឧបត្ថម្ភគាំទ្រ ថវិកាពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ជាមួយនេះ អង្គការសហប្រជាជាតិក៏មានគំរោងមួយ ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ដែលគំរោងនេះ គាំទ្រដល់មណ្ឌលសុខភាពនៅតាមឃុំ/សង្កាត់ចំនួន៣០០ នៃបណ្តាខេត្តអាទិភាព ដោយចាប់ផ្តើមធ្វើសកម្មភាពពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០( មានរយៈពេល៥ឆ្នាំ) ។

អនុវត្តតាមខ្លឹមសារកំណត់ហេតុនៃកិច្ចប្រជុំទ្វេភាគី កម្ពុជា-វៀតណាម( ថ្ងៃទី០៣-០៦ ខែវិច្ឆិកា ឆ្នាំ ២០០៩) នៅទីក្រុងហូជីមិញប្រទេសវៀតណាម នៅថ្ងៃទី២៥-២៩ខែឧសភាឆ្នាំ២០១០ អាជ្ញាធរជាតិបានចាត់ប្រតិភូអន្តរក្រសួងមួយក្រុម ទៅធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីកិច្ចការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

***-ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន***

-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមសំណើរបស់ក្រសួងសុខាភិបាលនិងវិទ្យាស្ថាន**Nosal** សំរាប់សុខភាពសកលនៃសកលវិទ្យាល័យ**Melborn**ប្រទេសអូស្ត្រាលី បានអនុញ្ញាតឱ្យធ្វើសម្ភាសន៍មន្ត្រីអាជ្ញាធរជាតិ ដើម្បី ប្រមូលទិន្នន័យសំរាប់គំរោងស្រាវជ្រាវស្តីពី ឥទ្ធិពលនៃកម្មវិធីកាត់បន្ថយគ្រោះថ្នាក់មកលើការអនុវត្តន៍ច្បាប់ ។ លទ្ធលនៃការស្រាវជ្រាវនេះ គឺដើម្បីផ្តល់ចំណេះដឹងផ្នែកវិទ្យាសាស្ត្រសំរាប់ជាប្រយោជន៍ដល់ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ។

## ***៤-ការពង្រឹងសមត្ថភាពអនុវត្តច្បាប់***

-អគ្គលេខាធិការដ្ឋាន អជបគញ បានសហការជាមួយអង្គការ UNODC បើកវគ្គបណ្តុះបណ្តាលចំនួន ២ វគ្គ មានរយៈពេល ២ ថ្ងៃ( វគ្គទី១ថ្ងៃទី២៥ខែឧសភា នៅក្រុងបាវិត ខេត្តស្វាយរៀង និង វគ្គទី២ថ្ងៃទី២៧ខែឧសភា នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ) ដល់អភិបាលរងខេត្តចំនួន៧រូប អភិបាលក្រុងប៉ោយប៉ែត កងនគរជាតិ មន្ត្រីក្រសួងបរិស្ថាន មន្ត្រីគយនិងរដ្ឋាករ មន្ត្រីកាំកុងត្រូល សរុបចំនួន ១២០ រូប ស្តីពីការប៉ាន់ប្រមាណភាពជាដៃគូមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ហៅកាត់ថា(PATROL) ។

## ***៥-កិច្ចសហប្រតិបត្តិការអន្តរជាតិ :***

អនុវត្តតាមអនុស្សារណៈនៃការយោគយល់គ្នាទ្វេភាគីកម្ពុជា-ចិន ដែលបានចុះហត្ថលេខាកាលពីខែវិច្ឆិកាឆ្នាំ២០០៨ អាជ្ញាធរជាតិ បានទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំលើកទី១ ( ថ្ងៃទី១៨ខែឧសភាឆ្នាំ២០១០) នៅសណ្ឋាគារកាំបូឌីយ៉ាណា ។

តាមរបៀបវារៈដែលបានគ្រោងទុក ភាគីទាំងពីរ បានធ្វើការបង្ហាញពីសភាពការណ៍គ្រឿងញៀនជូនគ្នាទៅវិញទៅមក និង បានពិនិត្យឡើងវិញលើកិច្ចសហប្រតិបត្តិការដែលនៅសេសសល់ក្នុងឆ្នាំកន្លងមក ជាពិសេសលើការងារបង្ក្រាបបទល្មើសគ្រឿងញៀន ។ ភាគីទាំងពីរក៏បានពិនិត្យ ពិភាក្សា យ៉ាងយកចិត្តទុកដាក់ទៅលើសំណូមពរមួយចំនួនដែលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរ និងបានឯកភាព ទី១-នឹងបន្តការផ្លាស់ប្តូរព័ត៌មានគ្រឿងញៀនទៅវិញទៅមកឱ្យបានជាក់លាក់និងទាន់ពេលវេលា ។ ២-ភាគីចិននឹងជួយបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ មន្ត្រីមន្ទីរពិសោធន៍គ្រឿងញៀន និង មន្ត្រីត្រួតពិនិត្យសារធាតុគីមីផ្សំ ដោយភាគីកម្ពុជាត្រូវលើកគំរោងស្នើសុំការបណ្តុះបណ្តាលនេះទៅភាគីចិន ព្រមទាំងបន្តជួយបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់កម្ពុជាចំនួន៣០នាក់ប្រចាំឆ្នាំ ។ ៣-ភាគីចិននឹងពាំនាំយកនូវសំណើសុំជួយសាងសង់អាគារទីស្តីការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សម្ភារៈ ការិយាល័យ បរិក្ខារពេទ្យ និង ថ្នាំព្យាបាលអ្នកញៀនគ្រឿងញៀន ដោយភាគីកម្ពុជាត្រូវលើកគំរោងស្នើសុំនេះទៅភាគីចិន តាមរយៈស្ថានទូតចិនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។ ៤-ភាគីចិនបានគាំទ្រគំរោងរៀបចំកម្មវិធីដំណាំជំនួសសំរាប់ការកាប់បំផ្លាញដើមម្រះព្រៅភ្នំខុសច្បាប់ និង យល់ព្រមទទួលស្វាគមន៍ដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនកម្ពុជា នៅប្រទេសចិន ។

ចុងបញ្ចប់នៃកិច្ចប្រជុំ ភាគីទាំងពីរបានចុះហត្ថលេខារួមគ្នា លើកណត់ហេតុនៃកិច្ចប្រជុំលើកទី១ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

ដើម្បីអនុវត្តបានសំរេចផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន នៅថ្ងៃទី២៧ខែឧសភា ឆ្នាំ២០១០ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបើកកិច្ចប្រជុំមួយ ក្រោមការដឹកនាំរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅទីស្តីការក្រសួងមហាផ្ទៃ ដើម្បីធ្វើការបូកសរុបលទ្ធផលការងារ និង ណែនាំពីការធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ។ លទ្ធផលជារួមគឺ : អង្គប្រជុំបានធ្វើការវាយតម្លៃខ្ពស់ ចំពោះភាពចាំបាច់នៃការអនុវត្តន៍នូវគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និង បានឯកភាពគ្នាលើទស្សនៈនៃការចាត់តាំងអនុវត្ត ដោយបានយល់ច្បាស់ពីគោលការណ៍ប្រឡងប្រណាំង គឺធ្វើយ៉ាងណាឱ្យឃុំ-សង្កាត់ពីមួយថ្ងៃទៅមួយថ្ងៃ មានការប្រែប្រួលពីពណ៌ខ្មៅ(មិនល្អ) ទៅជាពណ៌ប្រផេះ(ល្អមធ្យម) ពីពណ៌ប្រផេះមកជាពណ៌ស(គ្មានគ្រឿងញៀន) និង ពីពណ៌ក្រហម(មិនល្អ) ទៅជាពណ៌លឿង(ល្អមធ្យម) ពីពណ៌លឿងមកជាពណ៌បៃតង(គ្មាន គ្រឿងញៀន) សំរាប់គោលដៅសាលារៀន សណ្ឋាគារ កន្លែងសប្បាយនានា ។

ថ្នាក់ជាតិបានកំណត់យកខេត្តបន្ទាយមានជ័យ ធ្វើជាខេត្តដកពិសោធន៍ ដោយត្រូវជ្រើសរើសស្រុកគំរូមួយសំរាប់រាជធានី-ខេត្តដទៃចុះទៅសិក្សាស្វែងយល់ ។ ថ្នាក់រាជធានី-ខេត្ត ត្រូវជ្រើសរើសយកស្រុកមួយធ្វើជាស្រុកដកពិសោធន៍ ។ ដោយកំណត់យកឆ្នាំ២០១០នេះ ជាឆ្នាំចាប់ផ្តើមអនុវត្តការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន ។

## III . ការសន្និដ្ឋាន និង វាយតម្លៃ :

ក្នុងខែឧសភានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តយកចិត្តទុកដាក់អនុវត្តនូវការងារដែលនៅសេសសល់ពីខែមេសាឆ្នាំ២០១០ ទទួលបានលទ្ធផលល្អក្នុងការងារត្រួតពិនិត្យគ្រឿងញៀន ។ បណ្តាក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងនានា កាន់តែមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់លើការផ្សព្វផ្សាយអប់រំ ពីគ្រោះថ្នាក់នៃគ្រឿងញៀន និងបង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀនយ៉ាងផុលផុស និងចំគោលដៅ ចំមុខ សញ្ញាដែលងាយទទួលរងគ្រោះ ។ ប៉ុន្តែយើងនៅមិនទាន់បានអនុវត្តការផ្សព្វផ្សាយអប់រំនេះ ឱ្យបានស៊ីជម្រៅនៅ តាមគោលដៅផ្ទះសំណាក់ សណ្ឋាគារ កន្លែងសប្បាយនានា រួមទាំងការធ្វើកិច្ចសន្យារដ្ឋបាលឱ្យបានម៉ឹងម៉ាត់ជាមួយ ម្ចាស់មូលដ្ឋានអាជីវកម្មទាំងនោះ ជាហេតុធ្វើឱ្យពួកឈ្មួញគ្រឿងញៀន ក៏ដូចអ្នកប្រើប្រាស់គ្រឿងញៀន ឆ្លៀតយកទីនោះធ្វើជាកន្លែងជួញដូរនិងចែកចាយគ្រឿងញៀន ។ ជាមួយនេះ យើងបានបន្តយកចិត្តទុកដាក់បង្ក្រាបបានបទល្មើសចរាចរចែកចាយ តូច មធ្យម ធំ និងបានប្រមូលផ្តុំក្តាប់សភាពការណ៍ មុខសញ្ញាប្រព្រឹត្តបទល្មើស ក្រុមក្មេងទំនើង រហូតមានករណីខ្លះយើងឈានទៅទប់ ស្កាត់បានមុនហេតុការណ៍កើតឡើង ។ ប៉ុន្តែការបង្ក្រាបរបស់យើង ភាគច្រើននៅមិនទាន់បានចំក្រុមមេខ្លោង ឬ ជនដែលនៅពីក្រោយខ្នង ជាឧទាហរណ៍ ការផលិតប្រេងម្រះព្រៅភ្នំ សកម្មភាពនេះយើងបានដឹងពីប្រភពផលិត កន្លែងស្តុកទុក នឹងបានចុះទៅបង្ក្រាបដល់ទីតាំងជាបន្តបន្ទាប់ ប៉ុន្តែយើងនៅតែរកមិនទាន់ឃើញជនមេខ្លោង ។

ចំពោះការងារព្យាបាល ចំណុចដែលជាការកត់សំគាល់ គឺរាជរដ្ឋាភិបាលបានសំរេចផ្តល់របបជីវភាពជូនជនរងគ្រោះដោយគ្រឿងញៀនដែលកំពុងសំរាកនៅក្នុងមណ្ឌលបណ្តោះអាសន្នសំរាប់អប់រំ បន្សាប និង ព្យាបាលគ្រឿងញៀន ។ ប៉ុន្តែយើងនៅមានបញ្ហាចំពោះមុខដែលត្រូវសហការជាមួយក្រសួងសុខាភិបាល ដើម្បីជំរុញការអនុវត្តន៏ឱ្យបានសំរេចនូវអនុសាសន៏របស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាអាទិ៍ ការបង្កើតបទដ្ឋានគំរូឯកភាពសំរាប់ផ្តល់សេវាថែទាំសុខភាពអ្នករងគ្រោះដោយសារគ្រឿងញៀន ការរៀបចំឱ្យមានជំពូកចំណាយថវិកាជាតិសំរាប់ទិញឱសថព្យាបាលអ្នកញៀនគ្រឿងញៀន ជាដើម ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១០ :

ដូចបានធ្វើការសន្និដ្ឋាន និង វាយតម្លៃ ពីសភាពការណ៍គ្រឿងញៀន និងចំណុចប្រឈមក្នុងការអនុវត្តន៏នូវយុទ្ធសាស្ត្រខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវទិសដៅដើម្បីអនុវត្តបន្តដូចតទៅ :

### *១. ការងារកាត់បន្ថយតម្រូវការគ្រឿងញៀន :*

-បន្តកិច្ចសហការនិងសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តន៏អនុសាសន៏ណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ក្នុងពិធីផ្ទេតំណែងប្រធានអាជ្ញាធរជាតិ និងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផល

ការងារត្រួតពិនិត្យគ្រឿងញៀន ក្នុងនោះនឹងបំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និង វិស័យឯកជនក្នុងការផ្សព្វផ្សាយអប់រំ លើកកំពស់ការយល់ដឹងពីគ្រឿងញៀន តាមរយៈ ការសរសេរសារអប់រំពីគ្រឿងញៀនបិទលើផលិតផលក្នុងស្រុក, ការសរសេរសារអប់រំគ្រឿងញៀនចាក់ផ្សាយតាមស្ថានីយ៍វិទ្យុ-ទូរទស្សន៍រដ្ឋ និង ឯកជន, សារព័ត៌មាន, ការបំផុសឱ្យសិល្បករ សិល្បការិនី ពិធីករ ពិធីការិនី បន្តនិងបង្កើនការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន, ការបំផុសឱ្យក្រុមហ៊ុនផលិតខ្សែភាពយន្ត ខារ៉ាអូខេ ចម្រៀងកាយវិការ សរសេរសារអប់រំពីគ្រឿងញៀនដាក់នៅក្បាល Casette វីដេអូ ជាដើម ។ល។

-បន្តសហការជាមួយស្ថានីយ៍ ទូរទស្សន៍ រដ្ឋ និង ឯកជន អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ក្នុងការផ្តល់នូវបទសម្ភាសន៍ស្តីពីបញ្ហាគ្រឿងញៀននៅកម្ពុជា និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

-បន្តកិច្ចសហការនិងសម្របសម្រួល ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ដើម្បីធ្វើការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ឱ្យបានចំគោលដៅ និង ចំមុខសញ្ញា ដែលងាយរងគ្រោះដោយគ្រឿងញៀន ។

## ២-ការងារព្យាបាល ស្តារនីតិសម្បទា និង សមាហរណកម្ម និង ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន

-បន្តជំរុញការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តជំរុញការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការរៀបចំសេចក្តីព្រាងស្តីពីតំរូវការអប្បបរមាក្នុងការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តជំរុញការតម្លើងបញ្ជីឈ្មោះ ឃុំ សង្កាត់អាទិភាព សំរាប់ធ្វើសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅឆ្នាំ ២០១០, ឈ្មោះនិងទីតាំងមណ្ឌលសុខភាព, ឈ្មោះទីតាំងនិងវិសាលភាពនៃការអនុវត្តន៍ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារពាក់ព័ន្ធនឹងគ្រឿងញៀន និងជម្ងឺអេដស៍នៅរាជធានី-ខេត្ត ។

-សហការនិងសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នសំរាប់អប់រំ បន្សាប និង ព្យាបាលអ្នកញៀនគ្រឿងញៀនដែលមានស្រាប់ រួមទាំងការរៀបចំជំពូកចំណាយថវិកាជាតិសំរាប់ទិញឱសថព្យាបាលអ្នកញៀនគ្រឿងញៀន ។

-បន្តជំរុញការសាងសង់អាគារមន្ទីរពេទ្យ នៅក្នុងមណ្ឌលបណ្តោះអាសន្នសំរាប់អប់រំ បន្សាប និង ព្យាបាលអ្នកញៀនគ្រឿងញៀនរបស់ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ។

## ៣.ការពង្រឹងសមត្ថភាពអនុវត្តច្បាប់

-បន្តកិច្ចសហការ និង សម្របសម្រួលជាមួយភាគីអូស្រ្តាលី ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីអនុវត្តន៍ច្បាប់កម្ពុជា ពីជំនាញព័ត៌មានចារកម្ម ។

-បន្តកិច្ចសហការនិងសម្របសម្រួលជាមួយស្ថានទូតសហរដ្ឋអាមេរិក ក្នុងការស្នើសុំឱ្យជួយធានានិរន្តរភាពមន្ទីរពិសោធន៍គ្រឿងញៀនថ្នាក់ជាតិ និងការស្នើសុំមន្ទីរពិសោធន៍គ្រឿងញៀនថ្នាក់តំបន់ចំនួន២បន្ថែមទៀត ។

-សហការនិងសម្របសម្រួល ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ជំរុញឱ្យអាជ្ញាធរនៅមូលដ្ឋាន បន្តយកចិត្តទុកដាក់ធ្វើកិច្ចសន្យារដ្ឋបាលឱ្យបានម៉ឺងម៉ាត់ជាមួយម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត និង កន្លែងសប្បាយនានា ។

## ៤.កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី២ ស្តីពីបណ្តាញកោសល្យវិច័យវិទ្យាសាស្ត្រអាស៊ាន ដែលនឹងប្រព្រឹត្តទៅនៅប្រទេសប្រ៊ុយណេ (០១-០៣/៦/២០១០) ។

-ត្រៀមបញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីយុទ្ធសាស្ត្រផ្តល់ព័ត៌មានសំរាប់ការយល់ដឹងជាសាធារណៈនិងការបង្ការការពារអំពីគ្រោះថ្នាក់នៃគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅប្រទេសឥណ្ឌូនេស៊ី (ថ្ងៃទី៣១ ខែ ឧសភា ដល់ ថ្ងៃទី០៤ខែមិថុនាឆ្នាំ២០១០) ។

-ត្រៀមបញ្ជូនមន្ត្រីជាន់ខ្ពស់របស់អគ្គលេខាធិការដ្ឋាន អជបគញ ទៅចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ លើកទី២ ស្តីពីបណ្តាញកោសល្យវិច័យវិទ្យាសាស្ត្រអាស៊ាន នៅប្រទេសឥណ្ឌូនេស៊ី (ថ្ងៃទី០១-០៣ ខែមិថុនា ឆ្នាំ២០១០) ។

-ត្រៀមចាត់បញ្ជូនអ្នកសម្របសម្រួលកម្មវិធីអេដស៍ប្រចាំតំបន់អាស៊ី(HAARP)របស់អគ្គលេខាធិការដ្ឋាន អជបគញ ទៅចូលរួមក្នុងវេទិកាពិគ្រោះយោបល់ និងសម្របសម្រួលកម្មវិធីអេដស៍ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២២ ដល់ថ្ងៃទី២៤ខែមិថុនាឆ្នាំ២០១០ នៅទីក្រុងហាណូយប្រទេសវៀតណាម ។

-ត្រៀមបញ្ជូនមន្ត្រីទៅចូលរួមក្នុងសិក្ខាសាលា ស្តីពីកិច្ចសហប្រតិបត្តិការលើការអនុវត្តន៍គំរោងត្រួតពិនិត្យគ្រឿងញៀន (គំរោងក្របខណ្ឌសាធារណរដ្ឋកូរ៉េ) ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៨ ដល់ ថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០១០ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ។

## ៥.នីតិកម្ម :

បន្តកិច្ចសហការនិងសម្របសម្រួលជាមួយក្រសួងយុត្តិធម៌ ដើម្បីជំរុញការកែសំរួលសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឱ្យចប់ជាស្ថាពរ ។

ដើម្បីអនុវត្តបានសំរេចនូវផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀនខាងលើ អាជ្ញាធរជាតិនឹងបន្តជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងយកចិត្តទុកដាក់លើការងារសំខាន់ៗមួយចំនួនទៀត ជាអាទិ៍ ការពង្រឹងរចនាសម្ព័ន្ធនិងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋាន, ការត្រៀមរៀបចំកិច្ចប្រជុំដើម្បីអនុម័តលើផែនការប្រតិបត្តិនៅខេត្តបន្ទាយមានជ័យ នៅថ្ងៃទី០១-០៣ខែមិថុនាឆ្នាំ២០១០ ក្រោមការដឹកនាំរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**អគ្គលេខាធិការ**

**<u>ចំលងជូន</u> :**

-ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**

**-ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ**

**-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ**

(ដើម្បីជូនជ្រាប)

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ